គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត

របាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

**គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត**

**របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣**

| **មាតិកា** | **ទំព័រ** |
|---|---|
| របាយការណ៍ក្រុមប្រឹក្សាភិបាល | ១ - ៣ |
| របាយការណ៍សវនករឯករាជ | ៤ - ៥ |
| តារាងតុល្យការ | ៦ |
| របាយការណ៍លទ្ធផល | ៧ |
| របាយការណ៍បម្រែបម្រួលមូលធន | ៨ |
| របាយការណ៍លំហូរសាច់ប្រាក់ | ៩ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | ១០ - ៣៨ |
| ឧបសម្ព័ន្ធ ៖ កំណត់សម្គាល់ស្តីពីការអនុវត្តតាមប្រកាសរបស់ធនាគារកណ្តាល* | i – viiii |

*ឧបសម្ព័ន្ធមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មនេះទេ។

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត (ហៅកាត់ថា "ក្រុមហ៊ុន") សូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និង របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

### សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាមីក្រូហិរញ្ញវត្ថុទូលំទូលាយប្រកបដោយនិរន្តភាព និងប្រសិទ្ធភាពទៅដល់សហគ្រិនធុនតូចនិងមធ្យមដែលជាកសិករ សិប្បករ និងអាជីវករ ។

### លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ មានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល នៅលើទំព័រទី៧នៃរបាយការណ៍វត្ថុនេះ។

### ដើមទុនភាគហ៊ុន

ដើមទុនចុះបញ្ជី និងបានបង់ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល នៅក្នុងកំណត់សម្គាល់ ១៣ នៃរបាយការណ៍វត្ថុនេះ។

### ឥណទានអាក្រក់ និងឥណទានសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ពាក់ព័ន្ធទៅនឹងការជម្រះឥណទានអាក្រក់ចេញពីបញ្ជី និងការធ្វើសំវិធានធនឥណទានអាក្រក់និងសង្ស័យ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានអាក្រក់ទាំងអស់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនយ៉ាងពេញលេញ សម្រាប់ឥណទានអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលនាំឲ្យចំនួនឥណទានអាក្រក់ដែលបានជម្រះចេញពីបញ្ជី ឬចំនួនសំវិធានធនឥណទានអាក្រក់និងសង្ស័យ ក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

### ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថាបណ្តាលទ្រព្យសកម្មទាំងឡាយដែលទំនងជាមិនអាចបង្វិលមកវិញបាន នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ទៅតាមតម្លៃនៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាបន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថាអាចនឹងបង្វិលមកវិញបាន។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងអំពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឲ្យតម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ពុំត្រឹមត្រូវជាសារវន្តនោះទេ។


ផ្ទះលេខ១០១អា ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក ភ្នំពេញ
ADDRESS #101A, ST.289, BOEUNG KAK 1, TOUL KORK, PHNOM PENH
TEL: (855) 23 996 936 OR WEBSITE: WWW.CAMMA.COM.KH

**វិធីសាស្ត្រវាយតម្លៃ**

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលបានកើតឡើង ហើយអាចបណ្តាលឲ្យប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុលដែលមានស្រាប់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ ឬមិនសមស្របជាសារវន្តនោះទេ។

**បំណុលយថាភាព និងបំណុលផ្សេងៗ**

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះមិនមាន ៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក ឬ

ខ. បំណុលយថាភាពណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងតាំងពីដំណាច់ឆ្នាំមក ក្រៅពីអ្វីដែលបានកើតឡើងនៅក្នុងដំណើរការអាជីវកម្មធម្មតា។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុន បានក្លាយជាការបង្ខំឲ្យសង ឬអាចនឹងត្រូវទាមទារឲ្យសងក្នុងរយៈពេល១២ខែបន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដល់ថ្ងៃកំណត់សងនោះទេ។

**ការប្រែប្រួលកាលៈទេសៈ**

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឲ្យចំនួនទឹកប្រាក់ ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

**ប្រតិបត្តិការមិនប្រក្រតី**

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលពីដំណាច់ឆ្នាំ រហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយ-ការណ៍នេះ មិនមានខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងឆ្នាំនេះទេ។

**ក្រុមប្រឹក្សាភិបាល**

សមាជិកក្រុមប្រឹក្សាភិបាលដែលនៅបម្រើការក្នុងអំឡុងឆ្នាំ និងគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

- លោក ប៉ែនសុន សម័យ — ប្រធានក្រុមប្រឹក្សាភិបាល
- លោកស្រី ខាត់ សុខគាន — អនុប្រធានក្រុមប្រឹក្សាភិបាល
- លោក ធន់ វឌ្ឍនា — សមាជិកក្រុមប្រឹក្សាភិបាល

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និងលទ្ធផលប្រតិបត្តិការ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

១. អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះ ឲ្យមានភាពស៊ីសង្វាក់គ្នា។

២. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន ស្តង់ដារគណនេយ្យកម្ពុជា និង គោលការណ៍ណែនាំរបស់ធនាគារកណ្តាល ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឲ្យមានភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនោះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣. រក្សាទុកកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធិភាព។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតយ៉ាងសមរម្យថា ក្រុមហ៊ុននឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មក្នុងពេលអនាគតដ៏ខ្លី និង

៥. បង្កើតគោលនយោបាយសំរាប់ក្រុមហ៊ុន ចូលរួមការសំរេចចិត្តសំខាន់ៗនិងសកម្មភាពរបស់ក្រុមប្រឹក្សាភិបាល ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ហើយធានាថាផលប៉ះពាល់ទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមរាល់តម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សម្គាល់ទាំងឡាយដែលភ្ជាប់មកជាមួយដែលបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និង គោលការណ៍ណែនាំចេញដោយធនាគារកណ្តាល ។

ជ.ក្រុមប្រឹក្សាភិបាល

លោក បែនសុន សម័យ
ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី ឌិត នីតា
អគ្គនាយិកា

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ: ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤

pwc

## របាយការណ៍សវនករឯករាជ
## ជូនភាគទុនិក គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត (ហៅកាត់ថា "ក្រុមហ៊ុន") រួមមានតារាងតុល្យការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ឆ្នាំ ព្រមទាំងកំណត់សម្គាល់ ដែលរួមមានសេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ផ្សេងៗទៀត។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឲ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំ ចេញដោយធនាគារកណ្តាល និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឲ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

### ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំគឺបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដោយផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា។ ស្តង់ដារទាំងនោះ តម្រូវឲ្យយើងខ្ញុំប្រតិបត្តិតាមក្រមសីលធម៌ ធ្វើផែនការសវនកម្ម និងធ្វើសវនកម្មដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុពុំមានលក្ខណៈខុសឆ្គងជាសារវន្ត។

ការធ្វើសវនកម្ម រួមមានការអនុវត្តនីតិវិធីដើម្បីទទួលបាននូវភស្តុតាងសវនកម្ម អំពីចំនួនទឹកប្រាក់ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការជ្រើសរើសនីតិវិធីទាំងនេះ គឺអាស្រ័យលើការវិនិច្ឆ័យរបស់សវនករ រាប់ទាំងការវាយតម្លៃលើហានិភ័យនៃភាពខុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង។ ក្នុងការវាយតម្លៃហានិភ័យទាំងនោះ សវនករបានពិចារណាទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលទាក់ទងទៅនឹងការរៀបចំ និងការបង្ហាញយ៉ាងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីរៀបចំនូវនីតិវិធីសវនកម្ម ដែលមានលក្ខណៈសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ ប៉ុន្តែពុំមានគោលបំណងបញ្ចេញមតិទៅលើប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាពនោះទេ។ សវនកម្មក៏រួមបញ្ចូលទាំងការវាយតម្លៃនូវភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យដែលធ្វើឡើងដោយគណៈគ្រប់គ្រង ក៏ដូចជាការវាយតម្លៃលើការបង្ហាញជាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងទទួលបាន គឺមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវដែលជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

*PricewaterhouseCoopers (Cambodia) Ltd.*
*35 Sihanouk Boulevard, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh, Cambodia*
*T: +855 (0)23 218 086, F: +855(0)23 211 594, www.pwc.com/kh*

pwc

## មតិយោបល់

តាមទស្សនៈរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានដាក់បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និងលទ្ធផលហិរញ្ញវត្ថុព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំ ចេញដោយធនាគារកណ្តាល។

ជ. PricewaterhouseCoopers (Cambodia) Ltd.

PricewaterhouseCoopers (Cambodia) Ltd.

គុយ លីម
នាយក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទៈ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤

## គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត

## តារាងតុល្យការ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

| | កំណត់ | ២០១៣ | | ២០១២ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | | ៥២.១២០ | ២០៨.២១៩ | ៣០.៨៤៤ | ១២៣.២២២ |
| សមតុល្យនៅធនាគារកណ្តាល | ៤ | ៤២.៧១៨ | ១៧០.៦៥៨ | ៤២.៦៨០ | ១៧០.៥០៧ |
| សមតុល្យនៅធនាគារផ្សេងៗ | ៥ | ៥១៦.៥៧១ | ២.០៦៣.៧០១ | ៦៤.៣០៥ | ២៥៦.៨៩៨ |
| ឥណទានអតិថិជន | ៦ | ៣.៥៥៩.៨៤៦ | ១៤.២២១.៥៨៥ | ២.៤៦៥.៨៩៣ | ៩.៨៥១.២៤៣ |
| ទ្រព្យសកម្មផ្សេងៗ | ៧ | ៧៥.៨៩៦ | ៣០៣.២០៥ | ៦៦.៥៤៧ | ២៦៥.៨៥៥ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៨ | ៥៩.៧០៨ | ២៣៨.៥៣៤ | ៥៩.១៥១ | ២៣៦.៣០៨ |
| ទ្រព្យសកម្មអរូបី | ៩ | ១.២១១ | ៤.៨៣៨ | ១.១៨៧ | ៤.៧៤២ |
| **ទ្រព្យសកម្មសរុប** | | ៤.៣០៨.០៧០ | ១៧.២១០.៧៤០ | ២.៧៣០.៦០៧ | ១០.៩០៨.៧៧៥ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់កម្ចី | ១០ | ៣.១៨៧.០០០ | ១២.៧៣២.០៦៥ | ១.៨០៥.០០០ | ៧.២១០.៩៧៥ |
| បំណុលផ្សេងៗ | ១១ | ៣៣.៦៨៧ | ១៣៤.៥៨០ | ២៣.១៨២ | ៩២.៦១២ |
| សំវិធានធនពន្ធលើប្រាក់ចំណេញ | ១២ | ៣៣.៦៤៥ | ១៣៤.៤១២ | ៧.២៣៥ | ២៨.៩០៤ |
| **បំណុលសរុប** | | ៣.២៥៤.៣៣២ | ១៣.០០១.០៥៧ | ១.៨៣៥.៤១៧ | ៧.៣៣២.៤៩១ |
| **មូលធន** | | | | | |
| ដើមទុន | ១៣ | ៨៥០.០០០ | ៣.៣៩៥.៧៥០ | ៨៥០.០០០ | ៣.៣៩៥.៧៥០ |
| ប្រាក់ចំណេញរក្សាទុក | | ២០៣.៧៣៨ | ៨១៣.៩៣៣ | ៤៥.១៩០ | ១៨០.៥៣៤ |
| **មូលធនសរុប** | | ១.០៥៣.៧៣៨ | ៤.២០៩.៦៨៣ | ៨៩៥.១៩០ | ៣.៥៧៦.២៨៤ |
| **បំណុល និងមូលធនសរុប** | | ៤.៣០៨.០៧០ | ១៧.២១០.៧៤០ | ២.៧៣០.៦០៧ | ១០.៩០៨.៧៧៥ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី១០ ដល់ទំព័រទី៣៨ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត

## របាយការណ៍លទ្ធផល
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

| | កំណត់ | ២០១៣ | | ២០១២ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ១៤ | ៦៤០.៨០១ | ២.៥៦០.០០០ | ៣៥១.៤៨៥ | ១.៤០៤.១៨៣ |
| ចំណាយការប្រាក់ | ១៥ | (១៩៨.២៥៤) | (៧៩២.០២៥) | (១០០.៩០០) | (៤០៣.០៩៦) |
| **ចំណូលការប្រាក់សុទ្ធ** | | ៤៤២.៥៤៧ | ១.៧៦៧.៩៧៥ | ២៥០.៥៨៥ | ១.០០១.០៨៧ |
| សំវិធានធនឥណទានអាក្រក់ និងសង្ស័យ | ៦ | (១០.៨៤៩) | (៤៣.៣៤២) | (៣២.៥៣៧) | (១២៩.៩៨៥) |
| **ចំណូលការប្រាក់សុទ្ធបន្ទាប់ពី សំវិធានធនឥណទានអាក្រក់ និងសង្ស័យ** | | ៤៣១.៦៩៨ | ១.៧២៤.៦៣៣ | ២១៨.០៤៨ | ៨៧១.១០២ |
| ចំណូលប្រតិបត្តិការផ្សេងៗ | ១៦ | ២៥.២២៦ | ១០០.៧៧៨ | ៩.៣៧៨ | ៣៧.៤៦៥ |
| ចំណាយបុគ្គលិក | ១៧ | (១១២.៣៩៩) | (៤៤៩.០៣៤) | (៧៥.៥១១) | (៣០១.៦៦៦) |
| រំលស់ទ្រព្យសកម្មរូបី និងអរូបី | | (២១.៥១៨) | (៨៥.៩៦៤) | (៤.៩៣៣) | (១៩.៧០៧) |
| ចំណាយទូទៅ និងរដ្ឋបាល | ១៨ | (១២៤.៨២២) | (៤៩៨.៦៦៤) | (៦៨.៦៣៩) | (២៧៤.២១៣) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ** | | ១៩៨.១៨៥ | ៧៩១.៧៤៩ | ៧៨.៣៤៣ | ៣១២.៩៨១ |
| ពន្ធលើប្រាក់ចំណេញ | ១៩ | (៣៩.៦៣៧) | (១៥៨.៣៥០) | (១០.៣៩៥) | (៤១.៥២៩) |
| **ចំណេញក្នុងឆ្នាំ** | | ១៥៨.៥៤៨ | ៦៣៣.៣៩៩ | ៦៧.៩៤៨ | ២៧១.៤៥២ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី១០ ដល់ទំព័រទី៣៨ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត**

**របាយការណ៍បម្រែបម្រួលមូលធន**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣**

| | ដើមទុន<br>ដុល្លារអាមេរិក | ប្រាក់ចំណេញ<br>រក្សាទុក<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ | ៣៥០.០០០ | (២២.៧៥៨) | ៣២៧.២៤២ |
| ចំណេញក្នុងឆ្នាំ | - | ៦៧.៩៤៨ | ៦៧.៩៤៨ |
| ដើមទុនបានបង់បន្ថែមក្នុងឆ្នាំ | ៥០០.០០០ | - | ៥០០.០០០ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២** | ៨៥០.០០០ | ៤៥.១៩០ | ៨៩៥.១៩០ |
| **សមមូលជាពាន់រៀល** | ៣.៣៩៥.៧៥០ | ១៨០.៥៣៤ | ៣.៥៧៦.២៨៤ |
| | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ | ៨៥០.០០០ | ៤៥.១៩០ | ៨៩៥.១៩០ |
| ចំណេញក្នុងឆ្នាំ | - | ១៥៨.៥៤៨ | ១៥៨.៥៤៨ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣** | ៨៥០.០០០ | ២០៣.៧៣៨ | ១.០៥៣.៧៣៨ |
| **សមមូលជាពាន់រៀល** | ៣.៣៩៥.៧៥០ | ៨១៣.៩៣៣ | ៤.២០៩.៦៨៣ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី១០ ដល់ទំព័រទី៣៨ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត**

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

| | កំណត់ សម្គាល់ | ២០១៣ ដុល្លារអាមេរិក | ២០១៣ ពាន់រៀល | ២០១២ ដុល្លារអាមេរិក | ២០១២ ពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់បានប្រើក្នុងប្រតិបត្តិការ | ២០ | (១.៣១៥.០៨៨) | (៥.២៥៣.៧៧៨) | (២.០៩៧.៥៩០) | (៨.៣៧៩.៨៧៣) |
| ការប្រាក់បានទទួល | | ៦២៩.១៥០ | ២.៥១៣.៥១៤ | ៣៣១.០១១ | ១.៣២២.៣៨៩ |
| ការប្រាក់បានបង់ | | (១៨៧.១៤៦) | (៧៤៧.៦៤៨) | (៩៤.១៣៣) | (៣៧៦.០៦១) |
| ពន្ធលើប្រាក់ចំណេញបានបង់ | ១២ | (១៣.២២៧) | (៥២.៨៤២) | (៣.២៨៥) | (១៣.១២៤) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាព ប្រតិបត្តិការ | | (៨៨៦.៣២១) | (៣.៥៤០.៨៥៤) | (១.៨៦៣.៩៩៧) | (៧.៤៤៦.៦៦៩) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់តម្កល់ធានាលើដើមទុននៅ ធនាគារកណ្តាល | | - | - | (២៥.០០០) | (៩៩.៨៧៥) |
| បញ្ញើមានកាលកំណត់លើសពីបីខែ | | (២០០.០០០) | (៧៩៩.០០០) | - | - |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៨ | (២២.០៩៩) | (៨៨.២៨៦) | (៥៦.៣៣៤) | (២២៥.០៥៤) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាព វិនិយោគ | | (២២២.០៩៩) | (៨៨៧.២៨៦) | (៨១.៣៣៤) | (៣២៤.៩២៩) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ១.៩១៨.៥២៦ | ៧.៦៦៤.៥១២ | ២.០៣៥.០០០ | ៨.១២៩.៨២៥ |
| ការសងប្រាក់កម្ចី | | (៥៣៦.៥២៦) | (២.១៤៣.៤២១) | (៥៣០.០០០) | (២.១១៧.៣៥០) |
| សាច់ប្រាក់បានពីទុនបន្ថែម | | - | - | ៥០០.០០០ | ១.៩៩៧.៥០០ |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាព ហិរញ្ញប្បទាន | | ១.៣៨២.០០០ | ៥.៥២១.០៩១ | ២.០០៥.០០០ | ៨.០០៩.៩៧៥ |
| **កំណើនសុទ្ធសាច់ប្រាក់ និងសាច់ប្រាក់ សមមូលសុទ្ធ** | | ២៧៣.៥៨០ | ១.០៩២.៩៥១ | ៥៩.៦៦៩ | ២៣៨.៣៧៧ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល ដើមឆ្នាំ | | ៩៥.៣២៩ | ៣៨០.៨៣៩ | ៣៥.៦៦០ | ១៥២.៤៦២ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ២១ | ៣៦៨.៩០៩ | ១.៤៧៣.៧៩០ | ៩៥.៣២៩ | ៣៨០.៨៣៩ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី១០ ដល់ទំព័រទី៣៨ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

### ១. ព័ត៌មានទូទៅ

គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត (ហៅកាត់ថា "ក្រុមហ៊ុន") គឺជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១០ ដោយមានលេខចុះបញ្ជី ក.រ ០៧០០/ ខម ២០១០។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") ដើម្បីផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ។

ទស្សនវិស័យរបស់ក្រុមហ៊ុនគឺក្លាយទៅជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានទំនុកចិត្ត ដោយផ្តល់ឱកាសដើម្បីអភិវឌ្ឍន៍ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាតាមរយៈការផ្តល់ឥណទានពីក្រុមហ៊ុន។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់នូវសេវាមីក្រូហិរញ្ញវត្ថុប្រកបដោយនិរន្តភាពទៅដល់សហគ្រិនធុនតូច និងមធ្យមដែលជាកសិករ សិប្បករ និងអាជីវករ ។

ការិយាល័យកណ្តាលរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅអគារលេខ ១០១A ផ្លូវលេខ ២៨៩ សង្កាត់ បឹងកក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ក្រុមហ៊ុនមានបុគ្គលិកចំនួន ៣៧ នាក់ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ៖ ២៧ នាក់)។

### ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជូនដូចខាងក្រោម។ គោលការណ៍ទាំងនេះ ត្រូវបានអនុវត្តយ៉ាងស៊ីសង្វាក់គ្នា គ្រប់ឆ្នាំដែលបានបង្ហាញជូនទាំងអស់លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបាន បង្ហាញជា ដុល្លារអាមេរិក ("US$") និង ត្រូវបានរៀបចំតាមវិធីសាស្ត្រថ្លៃដើម។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុគឺត្រូវ អនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS") និងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល។

គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យ ដែលត្រូវបានគេទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេសផ្សេងទៀត និងយុត្តាធិការផ្សេងៗ។ របាយការណ៍ហិរញ្ញវត្ថុនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេងទៀត ក្រៅពីស្តង់ដារគណនេយ្យនៅព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះ របាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលស្របទៅតាមស្តង់ដារCAS តម្រូវឲ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល និងការលាតត្រដាងទ្រព្យសកម្ម និងបំណុលយថាភាពដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំនួននៃចំណូល និងចំណាយ ដែលបានរាយការណ៍នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។ ទោះបីជាការប៉ាន់ស្មានទាំងនេះផ្អែកទៅលើការយល់ដឹងដ៏សុក្រឹតបំផុតរបស់គណៈគ្រប់គ្រងតាមរយៈព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗ នាពេលបច្ចុប្បន្ន ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣។

### ២.២ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុថ្មី

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានប្រកាសដាក់ឲ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយ និងវិសោធនកម្មពាក់ព័ន្ធផ្សេងៗដែលអាចកើតមានក្នុងកាលៈទេសៈនានាចំពោះស្តង់ដារនីមួយៗ ដោយគ្រាន់តែបន្ថែមពាក្យ "កម្ពុជា"។ អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឲ្យស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ។

យោងតាមសារាចរណែនាំលេខ ០៨៦ សហវ-កជគ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុម័តឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពន្យារពេលអនុវត្ត CIFRS រហូតដល់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ឬការិយបរិច្ឆេទបន្ទាប់ពីនេះ។

របាយការណ៍ហិរញ្ញវត្ថុដំបូងរបស់ក្រុមហ៊ុន ដែលនឹងត្រូវរៀបចំតាម CIFRS គឺរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ ស្តង់ដារគណនេយ្យដែលក្រុមហ៊ុនប្រើប្រាស់នាពេលបច្ចុប្បន្ន គឺ CAS មានភាពខុសគ្នាជាច្រើនផ្នែក បើធៀបនឹង CIFRS។ ដូចនេះការអនុវត្ត CIFRS នឹងបណ្តាលឲ្យមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

### ២.៣ ការប្តូររូបិយប័ណ្ណ

#### (ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ក្រុមហ៊ុន។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៣ ការប្តូររូបិយប័ណ្ណ (ត)

### (ខ) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់ដាក់បង្ហាញ ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាត ដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

### (គ) ការបង្ហាញជារូបិយវត្ថុខ្មែរ រៀល

ដោយអនុលោមទៅតាមប្រកាសលេខ ប.៧ឥ០៧ឥ១៦៤ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០០៧ របស់ធនាគារកណ្តាលការប្តូររូបិយប័ណ្ណទៅជារូបិយវត្ថុជាតិ រៀល គឺត្រូវប្រើប្រាស់សម្រាប់ តារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់ និង កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនាសម្រាប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៣ ដោយប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការ រៀបរៀងដោយធនាគារកណ្តាល នៅកាលបរិច្ឆេទចេញរបាយការណ៍ ដែល១ដុល្លារអាមេរិក ស្មើនិង ៣.៩៩៥រៀល (ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១២: ១ដុល្លារអាមេរិក ស្មើនិង៣.៩៩៥ រៀល)។ របាយការណ៍ហិរញ្ញវត្ថុដែលបានរាយការណ៍ជាប្រាក់រៀល មិនមែនជាផ្នែកនៃរបាយការណ៍ដែលបានធ្វើសវនកម្មទេ ហើយមិនគួរបកស្រាយថាតួលេខនេះជាតួលេខសម្រាប់ បង្ហាញដូចតួលេខជាប្រាក់ដុល្លារអាមេរិក ឬយល់ថាជាតួលេខ ត្រូវបានប្តូរឬអាចប្តូរនាពេលអនាគតទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ដទៃទៀត។

### ២.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

គណនីសាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ សមតុល្យមិនជាប់កម្រិតនៅធនាគារកណ្តាល សមតុល្យនៅធនាគារផ្សេងៗ ដែលមានកាលកំណត់ដើមរយៈពេលបីខែ ឬតិចជាង គិតពីថ្ងៃទទួលបានសាច់ប្រាក់ និងឥណទានវិបារូបន៍ ថ្ងៃដែលក្រុមហ៊ុនមានលទ្ធភាពពេញលេញ ក្នុងការដកសាច់ប្រាក់នោះមកប្រើប្រាស់តាមតម្រូវការទូទៅ។

### ២.៥ ឥណទានអតិថិជន

ឥណទានអតិថិជនត្រូវបានរាយការណ៍ក្នុងតារាងតុល្យការ តាមចំនួនទឹកប្រាក់ដើម ដកចំនួនដែលបានជម្រះចេញពីបញ្ជី និងសំវិធានធនឥណទានអាក្រក់ និងសង្ស័យ។

ភាពគ្រប់គ្រាន់នៃសំវិធានធនសម្រាប់ឥណទានអាក្រក់ និងសង្ស័យត្រូវបានធ្វើការវាយតម្លៃប្រចាំខែដោយគណៈគ្រប់គ្រង។ សំវិធានធនឥណទានអាក្រក់ និងសង្ស័យកត់ជាចំណាយផ្អែកលើការវិនិច្ឆ័យរបស់គណៈគ្រប់គ្រងនូវចំនួនដែលចាំបាច់ ដើម្បីរក្សាសមតុល្យសំវិធានធននៅកម្រិតគ្រប់គ្រាន់ ដែលអាចមានឥណទានអតិថិជនដែលបាត់បង់។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៦ សំវិធានធនឥណទានអាក្រក់ និងសង្ស័យ

ក្រុមហ៊ុនបានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន តាមតម្រូវការរបស់ប្រកាសលេខ ធ៧-០២-១៨៦ប្រ.ក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២។ ប្រកាសនេះតម្រូវឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងឡាយ ធ្វើចំណាត់ថ្នាក់សំពៀតឥណទានរបស់ខ្លួនជាបួនថ្នាក់ ដោយផ្អែកទៅតាមចំនួនថ្ងៃដែលបានផុតកំណត់ចំពោះការសងប្រាក់ដើម និង/ឬការប្រាក់ដូចខាងក្រោម ៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលផុតកំណត់ | សំវិធានធន |
|---|---|---|
| ឥណទានរយៈពេលខ្លី (តិចជាង១ឆ្នាំ) | | |
| ស្តង់ដារ | តិចជាង ៣០ ថ្ងៃ | 0% |
| ក្រោមស្តង់ដារ | លើស ៣០ ថ្ងៃ តិចជាង ៦០ថ្ងៃ | ១០% |
| សង្ស័យ | លើស ៦០ ថ្ងៃ តិចជាង ៩០ថ្ងៃ | ៣០% |
| បាត់បង់ | លើស ៩០ ថ្ងៃ | ១០០% |
| | | |
| ឥណទានរយៈពេលវែង (លើសពី១ឆ្នាំ) | | |
| ស្តង់ដារ | តិចជាង ៣០ ថ្ងៃ | 0% |
| ក្រោមស្តង់ដារ | លើស ៣០ ថ្ងៃ តិចជាង ១៨០ថ្ងៃ | ១០% |
| សង្ស័យ | លើស ១៨០ ថ្ងៃ តិចជាង ៣៦០ថ្ងៃ | ៣០% |
| បាត់បង់ | លើស ៣៦០ ថ្ងៃ | ១០០% |

ឥណទាន ត្រូវបានជំរះបញ្ជីនៅពេលដែលគ្មានភាពប្រាកដទៅលើការប្រមូលបានមកវិញ។ ឥណទានដែលប្រមូលបានមកវិញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

### ២.៧ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានតត់ត្រាថ្លៃដើម ដករំលស់បង្គរ និងការខាតបង្គរដែលបណ្តាលមកពីការចុះថយតម្លៃ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗក្នុងការនាំយកទ្រព្យសម្បត្តិនោះ មកកាន់ទីតាំងនិងលក្ខខណ្ឌចាំបាច់ ដើម្បីឲ្យវាអាចធ្វើប្រតិបត្តិការទៅតាមការគ្រោងទុករបស់គណៈគ្រប់គ្រង។

ចំណាយបន្តបន្ទាប់ផ្សេងៗ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យដាច់ដោយឡែកតាមការសមស្រប តែនៅពេលដែលមានភាពប្រាកដប្រជាថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះនឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយថ្លៃដើមនៃទ្រព្យនោះ អាចត្រូវបានវាស់វែងគួរឲ្យជឿជាក់បានតែប៉ុណ្ណោះ។ ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល ក្នុងឆ្នាំដែលប្រតិបត្តិការនោះកើតឡើង។

ការធ្វើរំលស់នៃទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យសកម្ម តាមវិធីសាស្ត្ររំលស់ថេរ និងអត្រាប្រចាំឆ្នាំដូចខាងក្រោម ៖

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៧ ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

| | |
|---|---|
| ការកែលម្អទីកន្លែងជួល | ២៥% |
| កុំព្យូទ័រ និង បរិក្ខារផ្នែកពិតមានវិទ្យា | ២៥% |
| គ្រឿងសង្ហារឹម និងបរិក្ខារ | ២៥% |

តម្លៃសំណល់និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ និងធ្វើនិយ័តកម្មតាមការសមស្រប ប្រសិនបើមានសញ្ញាណនៃការប្រែប្រួលជាសារវន្តណាមួយ ចាប់តាំងពីកាលបរិច្ឆេទរបាយការណ៍មុនមក។

តម្លៃយោងនៃទ្រព្យសកម្មណាមួយ ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបានរបស់វា ត្រូវបានកត់ត្រាបន្ថយភ្លាមឱ្យនៅត្រឹមតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបាន។

ចំណេញ និងខាតពីការលក់ជម្រះទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់បានពីការលក់ និងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

### ២.៨ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីរួមមាន កម្មវិធីកុំព្យូទ័រ និងកម្រៃអាជ្ញាប័ណ្ណ ហើយត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់បង្គរ និងតម្លៃមកពីការថយចុះតម្លៃបង្គរ។ ការទិញកម្មវិធីកុំព្យូទ័រ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានទិញ និងយកកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។ ទ្រព្យសកម្មអរូបី ត្រូវបានធ្វើរំលស់ដោយប្រើវិធីសាស្ត្ររំលស់ថេរដោយអត្រារំលស់ ២៥% ក្នុងមួយឆ្នាំ។

### ២.៩ ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយដែលផ្តល់អត្ថប្រយោជន៍ មិនត្រូវបានធ្វើរំលស់ និងសាកល្បងទៅលើការថយចុះតម្លៃជារៀងរាល់ឆ្នាំឡើយ។ទ្រព្យសកម្មទាំងឡាយណាដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះរបស់វានៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាតម្លៃយោងរបស់វា នឹងមិនអាចយកមកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាមចំនួនលម្អៀងរវាងតម្លៃយោងនៃទ្រព្យនោះ ធៀបជាមួយតម្លៃដែលអាចយកមកវិញបាន។ តម្លៃដែលអាចយកមកវិញបាន គឺជាតម្លៃមួយណាដែលខ្ពស់ជាងគេ រវាងតម្លៃសមរម្យនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់។ ក្នុងការវាយតម្លៃដើម្បីរកការថយចុះ ទ្រព្យសម្បត្តិទាំងឡាយត្រូវបានបែងចែកជាក្រុមតូចៗបំផុត ដើម្បីកំណត់ពីលំហូរសាច់ប្រាក់របស់វានីមួយៗ (ឯកតាបង្កើតសាច់ប្រាក់)។

### ២.១០ ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាតាមចំនួនប្រាក់ដើមដែលមិនទាន់ទូទាត់។ ប្រាក់កំរៃដែលកើតឡើងពេលទទួលយកប្រាក់កម្ចីត្រូវបានចាត់ទុកជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១១ សំវិធានធន

សំវិធានធនត្រូវបានកត់ត្រានៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ដែលទំនងជាអាចតម្រូវឲ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឲ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល។ សំវិធានធនត្រូវបានកត់ត្រា ទោះបីជាកម្រិតលំហូរចេញនៃខ្ទង់ណាមួយនៅក្នុងចំណាត់ថ្នាក់កាតព្វកិច្ចដូចគ្នានោះ មានចំនួនតូចក៏ដោយ។

### ២.១២ ពន្ធលើប្រាក់ចំណេញ

#### (ក) ពន្ធចរន្តលើប្រាក់ចំណេញ

ពន្ធចរន្តលើប្រាក់ចំណេញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល គណនាផ្អែកលើមូលដ្ឋានដែលអនុម័តតាមច្បាប់ពន្ធ និងអនុម័តយ៉ាងសំខាន់នៅក្នុងតារាងតុល្យការដែលក្រុមហ៊ុនបានប្រតិបត្តិការ និងបង្កើតចំណូលពន្ធ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

#### (ខ) ពន្ធពន្យារលើប្រាក់ចំណេញ

ពន្ធពន្យារលើប្រាក់ចំណេញត្រូវបានធ្វើសំវិធានធនពេញលេញ ដោយប្រើវិធីសាស្ត្របំណុលលើលម្អៀងបណ្តោះអាសន្នដែលបានកើតឡើង រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យារលើប្រាក់ចំណេញ ត្រូវបានវាស់វែងតាមអត្រាពន្ធ (និងច្បាប់) ដែលបានអនុម័តរួចរាល់ ឬអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ ដែលរំពឹងថានឹងត្រូវអនុវត្តនៅពេលដែលពន្ធពន្យារលើប្រាក់ចំណេញពាក់ព័ន្ធត្រូវបានកត់ត្រា ឬនៅពេលដែលបំណុលពន្ធពន្យារលើប្រាក់ចំណេញត្រូវបានទូទាត់។ ពន្ធពន្យារលើប្រាក់ចំណេញត្រូវបានគណនាដោយប្រើអត្រាពន្ធ២០%។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកាត់កងជាមួយនឹងបំណុលពន្ធពន្យារ ប្រសិនបើមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីកាត់កងពន្ធទ្រព្យសកម្មក្នុងឆ្នាំ ជាមួយនឹងបំណុលពន្ធក្នុងឆ្នាំ ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណេញដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធតែមួយ។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថានឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត សម្រាប់យកលម្អៀងបណ្តោះអាសន្នមកប្រើប្រាស់។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយទៅតាមទំហំដែលទំនងជាមិនមានប្រាក់ចំណេញជាប់ពន្ធត្រូវបានកត់ត្រាទៀត។

### ២.១៣ ការទទួលស្គាល់ចំណូលនិងចំណាយការប្រាក់

ចំណូលការប្រាក់ពីឥណទាន ត្រូវបានគេកត់ត្រាតាមមូលដ្ឋានបង្គរ។ នៅពេលដែលឥណទានក្លាយជាឥណទាន មិនដំណើរការ ការទទួលស្គាល់ការប្រាក់ត្រូវបានពន្យាររហូតដល់ដែលវាទទួលស្គាល់ទៅតាមមូលដ្ឋាននៃសាច់ប្រាក់។

ចំណាយការប្រាក់ទៅលើកម្ចីត្រូវបានគេកត់ត្រា តាមមូលដ្ឋានបង្គរ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៤ ចំណូលជើងសារ

ចំណូលកម្រៃជើងសារត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ នៅពេលដែលសេវាកម្មត្រូវផ្តល់ឱ្យអតិថិជន។ កម្រៃដំណើរការឥណទាន ត្រូវបានទទួលស្គាល់ជាចំណូលនៅពេលដែលឥណទានបាន ផ្តល់ ឲ្យអតិថិជន។

### ២.១៥ ភតិសន្យា

ភតិសន្យាដែលភាគីម្ចាស់ទ្រព្យនៅមានហានិភ័យជាក់លាក់ និងផលកម្មសិទ្ធិលើទ្រព្យនេះ ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិ (ដកចេញនូវប្រាក់លើកទឹកចិត្តដែលទទួលបានពីភាគីម្ចាស់ជួល) ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផលតាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា។

### ២.១៦ ប្រតិបត្តិការភាគីពាក់ព័ន្ធ

ភាគីដែលត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធ ប្រសិនបើភាគីនោះមានលទ្ធភាពដោយផ្ទាល់ក្តីឬដោយប្រយោលក្តី ក្នុងការគ្រប់គ្រងភាគីមួយផ្សេងទៀត ឬមានឥទ្ធិពលជាសារវន្តលើភាគីមួយផ្សេងទៀតក្នុងការសម្រេចចិត្តលើផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុ ឬប្រសិនបើក្រុមហ៊ុននិងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួម ឬស្ថិតនៅក្រោមឥទ្ធិពលជាសារវន្តរួមគ្នាតែមួយ។ ភាគីពាក់ព័ន្ធអាចជាឯកបុគ្គលឬជាក្រុមហ៊ុន រាប់ទាំងសមាជិកគ្រួសារជិតដិតរបស់បុគ្គលនោះក៏ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធដែរ។

អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ភាគីពាក់ព័ន្ធត្រូវបានឲ្យនិយមន័យថាជាភាគីទាំងឡាយណាដែលកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោល យ៉ាងហោចណាស់១០% នៃដើមទុនរបស់ធនាគារ ឬមានសិទ្ធិបោះឆ្នោត រួមទាំងឯកបុគ្គលដែលមានតួនាទីក្នុងអភិបាលកិច្ច ការដឹកនាំ ការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

## ៣. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាកន្លងមក និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកនៃព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។ ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន សន្មត និងវិនិច្ឆ័យទៅពេលអនាគត។ ការប៉ាន់ស្មាន សន្មត និងវិនិច្ឆ័យដែលមានហានិភ័យសំខាន់នាំឲ្យមានការកែសម្រួលជាសារវន្តទៅលើ តម្លៃយោងនៃទ្រព្យសកម្មនិងបំណុលនៃឆ្នាំសារពើពន្ធត្រូវបានពិភាក្សានៅខាងក្រោម។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣**

## ៣. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

### (ក) ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ នៃឥណទានអតិថិជន

ក្រុមហ៊ុនអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទានសំវិធានធន ដោយយោងទៅតាមប្រកាសលេខ ធ៧-០២-១៨៦ប្រ.ក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ចេញដោយធនាគារកណ្តាលស្តីពីការធ្វើចំណាត់ថ្នាក់ និងសំវិធានធនឥណទានអាក្រក់ និងសង្ស័យ។ ធនាគារកណ្តាលតម្រូវឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងឡាយ ធ្វើចំណាត់ថ្នាក់សំពៀតឥណទានរបស់ខ្លួនជាបួនថ្នាក់ ហើយត្រូវប្រាកដថាគ្រឹះស្ថានរបស់ខ្លួនបានបំពេញកាតព្វកិច្ចសំវិធានធនជាក់លាក់អប្បបរមា អាស្រ័យលើការធ្វើចំណាត់ថ្នាក់ពាក់ព័ន្ធ។ ក្នុងការធ្វើចំណាត់ថ្នាក់ឥណទាន តម្រូវឲ្យក្រុមហ៊ុនគិតពិចារណាទៅលើប្រវត្តិនៃការសងប្រាក់ និងលក្ខខណ្ឌហិរញ្ញវត្ថុរបស់អ្នកខ្ចីប្រាក់។

### (ខ) ពន្ធ

ពន្ធត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ ប៉ុន្តែបទប្បញ្ញត្តិទាំងអស់នេះមានការផ្លាស់ប្តូរពីគ្រាមួយទៅគ្រាមួយទៀត ហើយការសម្រេចជាចុងក្រោយលើចំនួនពន្ធ នឹងធ្វើឡើងបន្ទាប់ពីសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយ ខុសគ្នាពីចំនួនដែលបានកត់ត្រាពីដំបូង នោះភាពលម្អៀងនេះ នឹងធ្វើឱ្យប៉ះពាល់ដល់ពន្ធលើប្រាក់ចំណេញ និងសំវិធានធនពន្ធពន្យារនៅក្នុងឆ្នាំ ដែលការកំណត់ពន្ធបានធ្វើឡើង។

## ៤. សមតុល្យនៅធនាគារកណ្តាល

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់តម្កល់ធានាលើដើមទុន (*) | ៤២.៥០០ | ១៦៩.៧៨៨ | ៤២.៥០០ | ១៦៩.៧៨៨ |
| គណនីចរន្ត | ២១៨ | ៨៧០ | ១៨០ | ៧១៩ |
| | ៤២.៧១៨ | ១៧០.៦៥៨ | ៤២.៦៨០ | ១៧០.៥០៧ |

### (*) ប្រាក់តម្កល់ធានាលើដើមទុន

អនុលោមតាមប្រកាសលេខ ធ៧០០-០៦ ប្រ.ក. ចេញដោយធនាគារកណ្តាលស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនត្រូវបានតម្រូវឲ្យរក្សាប្រាក់តម្កល់ធានាលើដើមទុននៅធនាគារកណ្តាលចំនួន ៥% នៃដើមទុនចុះបញ្ជី។ ប្រាក់តម្កល់ធានាលើដើមទុនទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំ គឺ ០.១១% (២០១២៖ ០.១២%)។

## ៥. សមតុល្យនៅធនាគារផ្សេងៗ

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| គណនីចរន្ត | ១៦៦.៥៧១ | ៦៦៥.៤៥១ | ៦៤.៣០៥ | ២៥៦.៨៩៨ |
| គណនីមានកាលកំណត់ | ៣៥០.០០០ | ១.៣៩៨.២៥០ | - | - |
| | ៥១៦.៥៧១ | ២.០៦៣.៧០១ | ៦៤.៣០៥ | ២៥៦.៨៩៨ |

### អត្រាការប្រាក់ប្រចាំឆ្នាំ

| | ២០១៣ | ២០១២ |
|---|---|---|
| គណនីចរន្ត | គ្មាន - 0.៧៥% | គ្មាន - 0.៧៥% |
| គណនីមានកាលកំណត់ | ២% - ២.២៥% | គ្មាន |

## ៦. ឥណទានអតិថិជន

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានរយៈពេលវែង | ៤៥.៧៣២ | ១៨២.៦៩៩ | ១៩.៧០៣ | ៧៨.៧១៣ |
| ឥណទានរយៈពេលខ្លី | ៣.៥១៩.១៨៣ | ១៤.០៥៩.១៣៦ | ២.៤៤៧.៥៩០ | ៩.៧៧៨.១២២ |
| | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |
| សំវិធានឥណទានអាក្រក់ និងសង្ស័យ | (៥.០៦៩) | (២០.២៥០) | (១.៤០០) | (៥.៥៩២) |
| | ៣.៥៥៩.៨៤៦ | ១៤.២២១.៥៨៥ | ២.៤៦៥.៨៩៣ | ៩.៨៥១.២៤៣ |

### (ក) សំវិធានធនឥណទានអាក្រក់និងសង្ស័យ

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ដើមឆ្នាំ | ១.៤០០ | ៥.៥៩៣ | ៤.៦៣៨ | ១៨.៥២៩ |
| បន្ថែម | ១០.៨៤៩ | ៤៣.៣៤២ | (៣.២៣៨) | (១២.៩៣៧) |
| *ឥណទានអាក្រក់ជម្រះចេញពីបញ្ជីក្នុងឆ្នាំ* | (៧.១៨០) | (២៨.៦៨៥) | - | - |
| ចុងឆ្នាំ | ៥.០៦៩ | ២០.២៥០ | ១.៤០០ | ៥.៥៩២ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

### ៦. ឥណទានអតិថិជន (ត)

(ខ) តាមកាលកំណត់ឥណទាន

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| មិនលើសពី១ខែ | ១១៩ | ៤៧៥ | ១.៣៥៨ | ៥.៤២៥ |
| លើសពី១ខែ តែមិនលើសពី៣ខែ | ២.៩៣៣ | ១១.៧១៧ | ២.១០៨ | ៨.៤២១ |
| លើសពី៣ខែ តែមិនមិនលើសពី១២ខែ | ១៣៤.១០៥ | ៥៣៥.៧៤៩ | ៧១.៣៥៤ | ២៨៥.០៥៩ |
| លើសពី១២ខែ | ៣.៤២៧.៧៥៨ | ១៣.៦៩៣.៨៩៤ | ២.៣៩២.៤៧៣ | ៩.៥៥៧.៩៣០ |
| | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |

(គ) តាមវិស័យអាជីវកម្ម

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ជំនួញ និងពាណិជ្ជកម្ម | ១.៥២៦.០២៤ | ៦.០៩៦.៤៦៦ | ៨៨២.៧៩៦ | ៣.៥២៦.៧៧០ |
| សេវាកម្ម | ៧០៩.៧៤៥ | ២.៨៣៥.៤៣១ | ៣៣៥.៧៨៩ | ១.៣៤១.៤៧៧ |
| កសិកម្ម | ២៤៥.៤៥៣ | ៩៨០.៥៨៥ | ២៨៤.៩៣៩ | ១.១៣៨.៣៣១ |
| ដឹកជញ្ជូន | ១៨២.៨៦៧ | ៧៣០.៥៥៤ | ១០៦.៦០៦ | ៤២៥.៨៩១ |
| សំណង់ | ៩៩.៧៥៩ | ៣៩៨.៥៣៧ | ៥០.៩៤៨ | ២០៣.៥៣៧ |
| គ្រួសារ | ៨.៤០០ | ៣៣.៥៥៨ | - | - |
| ផ្សេងៗ | ៧៩២.៦៦៧ | ៣.១៦៦.៧០៤ | ៨០៦.២១៥ | ៣.២២០.៨២៩ |
| | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |

(ឃ) តាមរូបិយប័ណ្ណ

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ដុល្លារអាមេរិក | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |
| | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

### ៦. ឥណទានអតិថិជន(ត)

### (ង) តាមទំនាក់ទំនង

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានបុគ្គលិក | ៣០.៤៣៣ | ១២១.៥៨០ | ៧.២៣០ | ២៨.៨៨៣ |
| អតិថិជនខាងក្រៅ | ៣.៥៣៤.៤៨២ | ១៤.១២០.២៥៥ | ២.៤៦០.០៦៣ | ៩.៨២៧.៩៥២ |
| | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |

### (ច) អត្រាការប្រាក់

អត្រាការប្រាក់ប្រចាំឆ្នាំ ដែលដាក់ឲ្យប្រតិបត្តិនៅក្នុងឆ្នាំ មានដូចខាងក្រោម ៖

| | ២០១៣ | ២០១២ |
|---|---|---|
| ឥណទានបុគ្គលិក | ១៥.៦០% | ១៥.៦០% |
| អតិថិជនខាងក្រៅ | ១៥.៦០% - ៣០% | ២០.៤% - ៣០% |

### (ឆ) តាមដំណើរការ

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានស្តង់ដារ | | | | |
| - មានវត្ថុធានា | ៣.៥០២.២១៨ | ១៣.៩៩១.៣៦១ | ២.៣៩៦.៩៩២ | ៩.៥៧៥.៩៨៣ |
| - គ្មានវត្ថុធានា | ៣០.៤៣៣ | ១២១.៥៨០ | ៥៨.៦៥៨ | ២៣៤.៣៣៩ |
| ឥណទានក្រោមស្តង់ដារ | | | | |
| - មានវត្ថុធានា | ២៣.០៥៣ | ៩២.០៩៧ | ១០.៤៥៩ | ៤១.៧៨៤ |
| - គ្មានវត្ថុធានា | - | - | - | - |
| ឥណទានសង្ស័យ | | | | |
| - មានវត្ថុធានា | ៩.២១១ | ៣៦.៧៩៧ | ១.១៨៤ | ៤.៧២៩ |
| - គ្មានវត្ថុធានា | - | - | - | - |
| | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |

## ៦. ឥណទានអតិថិជន(ត)

### (ជ) តាមទីតាំង

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រាជធានីភ្នំពេញ | ២.៦៤១.០១០ | ១០.៥៥០.៨៣៥ | ១.៦១១.២៨១ | ៦.៤៣៧.០៦៨ |
| ខេត្តកណ្តាល | ៩២៣.៩០៥ | ៣.៦៩១.០០០ | ៨៥៥.១៤០ | ៣.៤១៦.២៨៤ |
| ខេត្តកំពង់ស្ពឺ | - | - | ៨៧២ | ៣.៤៨៣ |
| | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |

### (ឈ) តាមហានិភ័យឥណទាន

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ហានិភ័យតូច | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |
| | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |

### (ញ) តាមស្ថានភាពនិវាសនជន

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| និវាសនជន | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |
| | ៣.៥៦៤.៩១៥ | ១៤.២៤១.៨៣៥ | ២.៤៦៧.២៩៣ | ៩.៨៥៦.៨៣៥ |

## ៧. ទ្រព្យសកម្មផ្សេងៗ

| | ២០១៣ | | ២០១២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ការប្រាក់ត្រូវទទួល | ៤០.១៤៩ | ១៦០.៣៩៥ | ២៧.២៤៦ | ១០៨.៨៤៨ |
| ការប្រាក់ត្រូវបានព្យួរ | (១.៩៦២) | (៧.៨៣៨) | (៧២០) | (២.៨៧៦) |
| ប្រាក់ត្រូវទទួលសុទ្ធ | ៣៨.១៨៧ | ១៥២.៥៥៧ | ២៦.៥២៦ | ១០៥.៩៧២ |
| ប្រាក់កក់ | ៣២.០៧៥ | ១២៨.១៤០ | ៣៦.៦៣០ | ១៤៦.៣៣៧ |
| ទ្រព្យសកម្មផ្សេងទៀត | ៥.៦៣៤ | ២២.៥០៨ | ៣.៣៩១ | ១៣.៥៤៦ |
| | ៧៥.៨៩៦ | ៣០៣.២០៥ | ៦៦.៥៤៧ | ២៦៥.៨៥៥ |

## គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីធីត

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

### ៨. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ការកែលម្អ ទីកន្លែងជួល | បរិក្ខារ ការិយាល័យ និង គ្រឿងសង្ហារឹម | កុំព្យូទ័រ និង បរិក្ខារផ្នែក ព័ត៌មានវិទ្យា | សរុប |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១២** | | | | |
| ថ្លៃដើម | - | ៤.៤២៥ | ៧.១៣០ | ១១.៥៥៥ |
| រំលស់បង្គរ | - | (១.៥៩៥) | (២.៦០៤) | (៤.១៩៩) |
| **តម្លៃចុះបញ្ជីសុទ្ធ** | - | ២.៨៣០ | ៤.៥២៦ | ៧.៣៥៦ |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២** | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | - | ២.៨៣០ | ៤.៥២៦ | ៧.៣៥៦ |
| ការទិញបន្ថែម | ៤៧.៩៤៧ | ១.៤២២ | ៦.៩៦៥ | ៥៦.៣៣៤ |
| ការជំរះបញ្ជីសុទ្ធ | - | (៣៥៦) | - | (៣៥៦) |
| រំលស់ | - | (១.៣២៦) | (២.៨៥៧) | (៤.១៨៣) |
| **តម្លៃចុះបញ្ជីសុទ្ធចុងគ្រា** | ៤៧.៩៤៧ | ២.៥៧០ | ៨.៦៣៤ | ៥៩.១៥១ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២** | | | | |
| ថ្លៃដើម | ៤៧.៩៤៧ | ៥.៤៩១ | ១៤.០៩៥ | ៦៧.៥៣៣ |
| រំលស់បង្គរ | - | (២.៩២១) | (៥.៤៦១) | (៨.៣៨២) |
| **តម្លៃចុះបញ្ជីសុទ្ធ** | ៤៧.៩៤៧ | ២.៥៧០ | ៨.៦៣៤ | ៥៩.១៥១ |
| **សមមូលជាពាន់រៀល** | ១៩១.៥៤៨ | ១០.២៦៧ | ៣៤.៤៩៣ | ២៣៦.៣០៨ |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣** | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៤៧.៩៤៧ | ២.៥៧០ | ៨.៦៣៤ | ៥៩.១៥១ |
| ការទិញបន្ថែម | ៧.២០៥ | ៦.០៣៥ | ៧.៨២៤ | ២១.០៦៤ |
| រំលស់ | (១២.៩១០) | (២.៣១៣) | (៥.២៨៤) | (២០.៥០៧) |
| **តម្លៃចុះបញ្ជីសុទ្ធចុងគ្រា** | ៤២.២៤២ | ៦.២៩២ | ១១.១៧៤ | ៥៩.៧០៨ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣** | | | | |
| ថ្លៃដើម | ៥៥.១៥២ | ១១.៥២៦ | ២១.៩១៩ | ៨៨.៥៩៧ |
| រំលស់បង្គរ | (១២.៩១០) | (៥.២៣៤) | (១០.៧៤៥) | (២៨.៨៨៩) |
| តម្លៃចុះបញ្ជីសុទ្ធ | ៤២.២៤២ | ៦.២៩២ | ១១.១៧៤ | ៥៩.៧០៨ |
| **សមមូលជាពាន់រៀល** | ១៦៨.៧៥៧ | ២៥.១៣៧ | ៤៤.៦៤០ | ២៣៨.៥៣៤ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

### ៩. ទ្រព្យសកម្មអរូបី

| | កុំព្យូទ័រ និង បរិក្ខារផ្នែក ព័ត៌មានវិទ្យា ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១២** | | |
